ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ : ៣២៧ ប្រក.កសក.ប

នាយកដ្ឋាន
ផលិតកម្ម & បសុព្យាបាល
ចូល លេខ ..1740.........
ថ្ងៃទី..14.|.04.|07.....
ម៉ោង..12.00.........

# ប្រកាស
## ស្តីពី
## ការប្រែក្លាយមជ្ឈមណ្ឌលស្រាវជ្រាវផ្នែកផលិតកម្ម និងបសុព្យាបាល ទៅជា វិទ្យាស្ថានជាតិស្រាវជ្រាវបសុព្យាបាល

## រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៩៦ ស្តីពីការរៀបចំ និងការ ប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការ ប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ១០៥ អនក្រ.បក ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ ២០០៥ ស្តីពីការបន្ថែមមុខងារ ភារកិច្ចឱ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងការបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុង នាយកដ្ឋានផែនការនិងស្ថិតិ នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងមជ្ឈមណ្ឌលព័ត៌មាននិងឯកសារកសិកម្ម ចំណុះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញប្រកាសលេខ ៩៨៨ ប្រក.កសកបុ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៣ ស្តីពីការរៀបចំនិងការ ប្រព្រឹត្តទៅរបស់នាយកដ្ឋានផលិតកម្ម និង បសុព្យាបាល
- បានឃើញប្រកាសលេខ ០២៣ ប្រក.កសក.បុ. ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ ២០០៣ ស្តីពីការបង្កើតមជ្ឈមណ្ឌលស្រាវជ្រាវផ្នែកផលិតកម្ម និងបសុព្យាបាល
- តាមសំណើរបស់នាយកដ្ឋានផលិតកម្ម និង បសុព្យាបាល

## សម្រេច

ប្រការ ១ : ត្រូវបានប្រែក្លាយមជ្ឈមណ្ឌលស្រាវជ្រាវផ្នែកផលិតកម្ម និងបសុព្យាបាល ទៅជាវិទ្យាស្ថានជាតិស្រាវជ្រាវបសុព្យាបាល ចំណុះនាយកដ្ឋានផលិតកម្ម និងបសុព្យាបាល នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលមានថ្នាក់ស្មើនិងមន្ទីរកសិកម្មខេត្ត ក្រុង ។

ប្រការ ២ : វិទ្យាស្ថានជាតិស្រាវជ្រាវបសុព្យាបាល មានតួនាទី ភារកិច្ចដូចតទៅ :

- រៀបចំផែនការ កម្មវិធីគំរោង វិធានការអភិវឌ្ឍន៍វិស័យស្រាវជ្រាវបសុព្យាបាល
- វិភាគជំងឺឆ្លងពីសត្វទៅមនុស្ស ពីមនុស្សទៅសត្វ និងពីសត្វទៅសត្វ

- ធ្វើរោគវិនិច្ឆ័យជំងឺសត្វ សារធាតុគីមី និងជីវគីមី
- វិភាគគុណភាពឱសថ
- វិភាគព័ត៌មានស្តីពីសុខភាពសត្វ
- ស្រាវជ្រាវ និងអង្កេតលើសុខភាពសត្វ
- ចូលរួមបណ្តុះបណ្តាល និងបំពាក់បំប៉នសមត្ថភាព អំពីការងារបច្ចេកទេសស្រាវជ្រាវបសុព្យាបាល
- សហការជាមួយស្ថាប័ន ឬ វិទ្យាស្ថាននានាដែលពាក់ព័ន្ធ អង្គការជាតិ និងអន្តរជាតិ សំរាប់ការស្រាវជ្រាវបសុព្យាបាល
- ចងក្រងឯកសារបច្ចេកទេសវិទ្យាសាស្ត្រស្រាវជ្រាវលើសុខភាពសត្វ
- ទទួលភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំនាយកដ្ឋានផលិតកម្ម និង បសុព្យាបាលប្រគល់ឱ្យ ។

វិទ្យាស្ថានជាតិស្រាវជ្រាវបសុព្យាបាល ដឹកនាំដោយនាយកមួយរូប និងអមដោយនាយករងមួយចំនួន ជាជំនួយការ ។

**ប្រការ ៣ :** វិទ្យាស្ថានជាតិស្រាវជ្រាវបសុព្យាបាល មានការិយាល័យចំនួន៣ និងមន្ទីរពិសោធន៍ចំនួន២ ដែលមានថ្នាក់ស្មើនឹងការិយាល័យចំណុះមន្ទីរកសិកម្មខេត្ត ក្រុង រួមមាន :

១-ការិយាល័យរដ្ឋបាល

២-ការិយាល័យវិភាគព័ត៌មានសុខភាពសត្វ

៣-ការិយាល័យរោគរាតត្បាតសាស្ត្រ

៤- មន្ទីរពិសោធន៍មីក្រុបសាស្ត្រ

៥- មន្ទីរពិសោធន៍ជីវគីមីសាស្ត្រ

**ប្រការ ៤ :** ការិយាល័យ និង មន្ទីរពិសោធន៍នីមួយៗ ដឹកនាំដោយប្រធានមួយរូប និងអមដោយអនុប្រធានមួយចំនួនជាជំនួយការ ។

ប្រធានការិយាល័យ ប្រធានមន្ទីរពិសោធន៍ ត្រូវទទួលខុសត្រូវចំពោះមុខនាយកវិទ្យាស្ថាននូវរាល់សកម្មភាពការងារនៅក្នុងការិយាល័យ និងមន្ទីរពិសោធន៍ ។

អនុប្រធានការិយាល័យ អនុប្រធានមន្ទីរពិសោធន៍ ជាអ្នកជំនួយការឱ្យប្រធាន ត្រូវបានប្រធានប្រគល់ការងារមួយចំនួនឱ្យទទួលបន្ទុក និងទទួលខុសត្រូវចំពោះមុខប្រធាន លើរាល់សកម្មភាពការងារ ហើយត្រូវរួមជាមួយប្រធានទទួលខុសត្រូវរាល់ការងារក្នុងការិយាល័យ និងមន្ទីរពិសោធន៍ ។

**ប្រការ ៥ :** តួនាទី ភារកិច្ចរបស់ការិយាល័យ និងមន្ទីរពិសោធន៍ មានដូចតទៅ :

**៥.១-<u>ការិយាល័យរដ្ឋបាល មានភារកិច្ច</u> :**

- គ្រប់គ្រង និងចាត់ចែងសេវារដ្ឋបាល ការងារបុគ្គលិកក្នុងវិទ្យាស្ថានជាតិ
- សម្របសម្រួលកិច្ចសហប្រតិបត្តិការរបស់វិទ្យាស្ថានជាមួយស្ថាប័នជាតិ អន្តរជាតិ
- រៀបចំផែនការស្រាវជ្រាវ និងតាមដានផែនការស្រាវជ្រាវរបស់វិទ្យាស្ថានជាតិ
- គ្រប់គ្រងបញ្ជិកាគណនេយ្យ និងថវិកាសម្រាប់ដំណើរការរបស់វិទ្យាស្ថានជាតិ
- គ្រប់គ្រងថែរក្សាចលនទ្រព្យ អចលនទ្រព្យ សម្ភិធិសម្ភារៈ ឧបករណ៍សម្ភារៈបរិក្ខារ និងធ្វើបញ្ជីសារពើភ័ណ្ឌរបស់វិទ្យាស្ថានជាតិ
- គ្រប់គ្រង និងផ្តល់សេវាបណ្ណាល័យ និងមូលដ្ឋានទិន្នន័យសំរាប់ការស្រាវជ្រាវបសុព្យាបាល
- ទទួលភារកិច្ចផ្សេងៗទៀតដែលថ្នាក់ដឹកនាំវិទ្យាស្ថានប្រគល់ឱ្យ ។

**៥.២-<u>ការិយាល័យវិភាគព័ត៌មានសុខភាពសត្វ មានភារកិច្ច</u> :**

- រៀបចំចងក្រងឯកសារ ព័ត៌មានសុខភាពសត្វ និងជំងឺឆ្លងសត្វដែលបានមកពីការសិក្សាស្រាវជ្រាវ

- គ្រប់គ្រងព័ត៌មានសុខភាពសត្វ និងជំងឺឆ្លងសត្វ
- សហការ និងសម្របសម្រួលក្នុងការផ្សព្វផ្សាយលទ្ធផលដែលបានមកពីការសិក្សាស្រាវជ្រាវ
- ទទួលបន្ទុកការងារបណ្តុះបណ្តាលបច្ចេកទេសជំងឺសត្វដែលបានមកពីការសិក្សាស្រាវជ្រាវ
- រៀបចំ ចងក្រង និងតំកល់ទុកឯកសារស្រាវជ្រាវពីសុខភាពសត្វ
- ទទួលភារកិច្ចផ្សេងៗទៀតដែលថ្នាក់ដឹកនាំវិទ្យាស្ថានប្រគល់ឱ្យ ។

**៥.៣-ការិយាល័យរោគរាតត្បាតសាស្ត្រ មានភារកិច្ច :**

- ស្រាវជ្រាវរកកន្លែងផ្ទុះជំងឺ និងប្រភពរាលដាលនិងរាតត្បាតនៃជំងឺសត្វ
- អង្កេតតាមដាន និងសិក្សាស្រាវជ្រាវនៅក្នុង និងនៅជុំវិញកន្លែងផ្ទុះជំងឺសត្វ
- ប្រមូលព័ត៌មាន និង វិភាគទិន្នន័យ ស្តីពីជំងឺសត្វ
- ចុះយកវត្ថុវិភាគ និងត្រួតពិនិត្យកន្លែងផ្ទុះជំងឺ
- គ្រប់គ្រងការស្តុកសេរ៉ូម
- គ្រប់គ្រងឯកសារដែលបានមកពីការអង្កេតតាមដាននិងស្រាវជ្រាវជំងឺសត្វ
- ធ្វើរបាយការណ៍ពីស្ថានភាពជំងឺសត្វ
- ទទួលភារកិច្ចផ្សេងៗទៀតដែលថ្នាក់ដឹកនាំវិទ្យាស្ថានប្រគល់ឱ្យ ។

**៥.៤-មន្ទីរពិសោធន៍មីក្រូបសាស្ត្រ មានភារកិច្ច :**

- វិភាគរកប្រភេទជំងឺ និងប្រភេទវីរុសដែលបង្កជំងឺលើសត្វ
- វិភាគរកជម្ងឺសត្វ ជាអាទិ៍ : ផ្នែកវីរុសសាស្ត្រ ផ្នែកបាក់តេរីសាស្ត្រ ផ្នែកសរីរៈរោគសាស្ត្រ ផ្នែកលោហិតសាស្ត្រ ផ្នែកសេរ៉ូមសាស្ត្រ និង ផ្នែកប៉ារ៉ាស៊ីតសាស្ត្រ ។
- ទទួលភារកិច្ចផ្សេងៗទៀតដែលថ្នាក់ដឹកនាំវិទ្យាស្ថានប្រគល់ឱ្យ ។

**៥.៥-មន្ទីរពិសោធន៍ជីវគីមីសាស្ត្រ មានភារកិច្ច :**

- វិភាគរកប្រភេទសារធាតុគីមី និងជីវគីមីដែលមាននៅក្នុងសត្វ និងក្នុងផលិតផលមានដើមកំណើតពីសត្វ
- វិភាគរកកាកសំណល់សារធាតុគីមីដែលមាននៅក្នុងសត្វ និងក្នុងផលិតផលមានដើមកំណើតពីសត្វ
- វិភាគរកសារធាតុគីមីដែលមានលាយនៅក្នុងចំណីសត្វ
- វិភាគគុណភាពបសុឱសថ
- ទទួលភារកិច្ចផ្សេងៗទៀតដែលថ្នាក់ដឹកនាំវិទ្យាស្ថានប្រគល់ឱ្យ ។

៦ : ប្រកាស ឬ សេចក្តីសម្រេចទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

៧ : អគ្គនាយកនៃក្រសួង អគ្គាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានបុគ្គលិក និងអភិវឌ្ឍន៍ធនធានមនុស្ស ប្រធាននាយកដ្ឋាននីតិកម្មកសិកម្ម ប្រធាននាយកដ្ឋានផលិតកម្ម និងបសុព្យាបាល និង ប្រធានគ្រប់អង្គភាពដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ... ខែ កុម្ភៈ ឆ្នាំ២០០៧

ចាន់ សារុន

**កន្លែងទទួល:**

...ការគណៈរដ្ឋមន្ត្រី
...សួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
...លេខាធិការដ្ឋានមុខងារសាធារណៈ
...ន្ទីរកសិកម្មគ្រប់ខេត្ត ក្រុង " ដើម្បីជូនជ្រាប "
...ប្រការ ៧ " ដើម្បីអនុវត្ត "
...ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម
រុក្ខាប្រមាញ់ និង នេសាទ

ឧបសម្ព័ន្ធនៃប្រកាសលេខ ៣២៧ ប្រក.កសក.ប ចុះថ្ងៃទី ០៦ ខែសីហា ឆ្នាំ ២០០៧

# អង្គការលេខរបស់វិទ្យាស្ថានជាតិស្រាវជ្រាវបសុព្យាបាល

